


# ព្រឹត្តិបត្រ ពណ៌ស្វាយ

ច្បាប់ទី ២៤ - ខែ សីហា ឆ្នាំ២០០៨

ព្រឹត្តបត្រប្រចាំខែរបស់ អង្គការខាណា

www.khana.org.kh


KHANA

អង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជំងឺអេដស៍

Khmer HIV/AIDS NGO Alliance

## ការមាក់ងាយជាចំណុចក្ដៅនៅក្នុងសន្និសីទអន្តរជាតិស្ដីពីជំងឺអេដស៍នៅម៉ិចស៊ិក្វ

ការក្រោកឈរឡើងដើម្បីទាមទារសិទ្ធិរបស់អ្នករស់នៅជាមួយមេរោគអេដស៍ និងអ្នកងាយរងគ្រោះនៅតែជាការងារចំពោះមុខសំរាប់សកម្មជនការងារអេដស៍នៅជុំវិញពិភពលោក។ ការមាក់ងាយ និងការរើសអើងគឺជាចំណុចដ៏សំខាន់ដែលត្រូវបានលើកយកមកពិភាក្សានៅឯសន្និសីទអន្តរជាតិស្ដីពីជំងឺអេដស៍លើកទី ១៧ នៅក្នុងទីក្រុងម៉ិចស៊ិកូកាលពីថ្ងៃទី ៣-៨ សីហា ២០០៨ កន្លងទៅនេះ។ ទោះបីជាសកម្មជនការងារអេដស៍ និងអ្នករៀបចំគោលនយោបាយបានខិតខំបំពេញការងារដើម្បីធ្វើឱ្យសាធារណៈបានយល់ដឹងច្បាស់ ហើយមិនភាន់ច្រឡំពីភាពមិនត្រឹមត្រូវចំពោះមេរោគនេះក៏ដោយ ក៏អ្នករស់នៅជាមួយមេរោគអេដស៍នៅតែប្រឈមនឹងការលំបាកជាងការដែលមានផ្ទុកជំងឺនោះទៅទៀត។

លោក Ban Ki-moon អគ្គលេខាធិការអង្គការសហប្រជាជាតិបាននិយាយនៅក្នុងសន្ទរកថាបើកសន្និសីទកាលពីថ្ងៃទី ៣ សីហា ថា "នៅក្នុងបណ្ដាប្រទេសភាគច្រើន ការមាក់ងាយដល់អ្នករស់នៅជាមួយមេរោគអេដស៍នៅតែជាការប្រឈមមួយដ៏ខ្លាំង។ មួយភាគបីនៃបណ្ដាប្រទេសទាំងនោះនៅតែមិនទាន់មានច្បាប់ការពារអ្នករស់នៅជាមួយមេរោគអេដស៍។...បញ្ហានេះត្រូវតែផ្លាស់ប្ដូរ"។

នៅក្នុងសន្ទរកថារបស់លោក លោកអគ្គលេខាបានផ្ដោតភាគច្រើនលើបញ្ហានៃការមាក់ងាយ និងការរើសអើង ដោយលោកបានអំពាវនាវដល់អ្នកនយោបាយនៅជុំវិញពិភពលោកឱ្យ "និយាយប្រឆាំងនឹងការរើសអើង ហើយការពារសិទ្ធិរបស់អ្នករស់នៅជាមួយមេរោគអេដស៍ និងអ្នកដែលរងការប៉ះពាល់ដោយមេរោគ

(តទៅទំព័រ ២)

## មាតិកា


ពិភពលោកត្រូវការ "ការរួបរួមគ្នា" ក្នុងការឆ្លើយតបនឹងអេដស៍ អង្គការខាណាក៏បានសន្យាចូលរួមនៅក្នុង "ការរួបរួមគ្នា" របស់ពិភពលោកដែរ ....................២

មេដឹកនាំប្រទេស G8 ទទួលសំពាធឱ្យមានការឆ្លើយតបនឹងអេដស៍ ....................៣

តើអ្វីជាសន្និសីទអេដស៍អន្តរជាតិ? ....................៤

វេទិកាអង្គការខាណា ....................៤


## បើគ្មានថ្នាំប្រឆាំងមេរោគអេដស៍ទេនោះគឺជាការលំបាកដល់អ្នករស់នៅជាមួយមេរោគអេដស៍



កុមារី ហៀង សុខហេង អាយុ ៨ ឆ្នាំកាន់ថ្នាំប្រឆាំងមេរោគអេដស៍នៅក្នុងដៃមុនពេលលេប។ សុខហេង ត្រូវបានរកឃើញថាមានផ្ទុកមេរោគអេដស៍តាំងពីនាងមានអាយុបានមួយខួបម្ល៉េះ។ ម្ដាយ និងប្អូនស្រីរបស់នាងបានស្លាប់ដោយសារជំងឺដែលទាក់ទងនឹងមេរោគអេដស៍តាំងពីប៉ុន្មានឆ្នាំមុនម្ល៉េះ។

កាន់ថ្នាំប្រឆាំងមេរោគអេដស៍នៅក្នុងដៃ ហៀង សុខហេង កុមារីកម្ពុជាមានវ័យ ៨ ឆ្នាំដែលម្ដាយ ហើយនិងប្អូនស្រីរបស់ខ្លួនបានស្លាប់ដោយជំងឺដែលទាក់ទងនឹងមេរោគអេដស៍អស់រយៈពេលជាច្រើនមកហើយនោះ បាននិយាយថា "យាយខ្ញុំឱ្យខ្ញុំលេបវារាល់ថ្ងៃ"។

រស់នៅជាមួយជីដូន សុខហេង ត្រូវបានគេធ្វើរោគវិនិច្ឆ័យឃើញថាមានផ្ទុកមេរោគអេដស៍កាលពីនាងមានអាយុបានមួយខួប។ អ្នកស្រី ឈឿ រឿន អាយុ ៥៨ ឆ្នាំ ជាជីដូនរបស់សុខហេង បាននិយាយថា "ចៅខ្ញុំមិនអាចរស់ដោយគ្មានថ្នាំនេះបានទេ។ បើគ្មានថ្នាំនេះវានឹងស្លាប់ដោយទុកឱ្យខ្ញុំនៅតែឯងហើយ"។

កុមារីនេះលេបថ្នាំប្រឆាំងមេរោគអេដស៍ក្នុងមួយថ្ងៃពីរដង គឺពេលព្រឹកមុនពេលទៅសាលាម្ដង និងមុនពេលចូលគេងម្ដងទៀត ហើយក៏បានលេបថ្នាំជំងឺឱកាសនិយមម្ដងដែរនៅរាល់ពេលបាយថ្ងៃ។ "បើគ្មានថ្នាំទាំងនេះទេ ចៅស្រីខ្ញុំមិនអាចរស់បានទេ" នេះជាសំដីរបស់ជីដូន ឈឿ រឿន ដែលបាននិយាយដោយហូរទឹកភ្នែកដោយគាត់បានបញ្ជាក់ថា "ថ្នាំប្រឆាំងមេរោគអេដស៍នេះបានផ្ដល់ឱ្យចៅខ្ញុំនូវឱកាសទី២ ដើម្បីរស់រានមានជីវិត គឺវាមិនអាចរស់ដោយគ្មានថ្នាំនេះបានទេ"។

(តទៅទំព័រ ៣)

USAID FROM THE AMERICAN PEOPLE

WFP United Nations World Food Programme

European Union

# ពិភពលោកត្រូវការ "ការរួបរួមគ្នា" ក្នុងការឆ្លើយតបនឹងអេដស៍

## អង្គការខាណាក៏បានសន្យាចូលរួមនៅក្នុង "ការរួបរួមគ្នា" របស់ពិភពលោកដែរ




*លោកវេជ្ជ. អ៊ុំ សុភាព (ស្តាំ) នាយកប្រតិបត្តិអង្គការខាណា ធ្វើបទបង្ហាញស្តីពីជោគជ័យរបស់ប្រទេសកម្ពុជា ជាពិសេសរបស់អង្គការខាណា ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅឯសន្និសីទអន្តរជាតិលើកទី ១៧ ស្តីពីជំងឺអេដស៍ ។ នៅក្នុងអំឡុងពេលនៃសន្និសីទរយៈពេល ៦ ថ្ងៃនេះ ខាណា មានបទបង្ហាញចំនួនបីផ្សេងគ្នា ស្តីពីសមិទ្ធផល និងការប្រឈមក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងប្រទេស ព្រមទាំងជំហានបន្ទាប់ ដើម្បីចូលរួមនៅក្នុង "ការរួបរួមគ្នា" របស់ពិភពលោកឆ្លើយតបនឹងវិបត្តិនេះ ។*

នាឱកាសជួបជុំគ្នាដ៏ធំមួយនៅឯសន្និសីទអន្តរជាតិស្តីពីជំងឺអេដស៍ លើកទី ១៧ ក្នុងប្រទេសម៉ិចស៊ិកូ នាដើមខែសីហា កន្លងមកនេះ មេដឹកនាំពិភពលោកត្រូវបានគេជំរុញឱ្យបង្កើត "ការរួបរួមគ្នា" ជាសកលដើម្បីប្រយុទ្ធនឹងវិបត្តិរួមគឺជំងឺអេដស៍ ។

ថ្លែងនៅក្នុងសន្ទរកថាបិទអង្គសន្និសីទ លោកវេជ្ជបណ្ឌិត Julio Montaner ប្រធានអង្គការសង្គមអន្តរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បាននិយាយថា ពាក្យដ៏សំខាន់ដែលកើតចេញពីសន្និសីទនេះគឺ "ការរួបរួមគ្នា" ។ លោក វេជ្ជ. Montaner បាននិយាយថា ការរួបរួមគ្នាចំនួនប្រាំចំណុចដែលមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការដោះស្រាយវិបត្តិនេះគឺការរួបរួមគ្នាក្នុងយុទ្ធសាស្ត្របង្ការ ដើម្បីកាត់បន្ថយនៃការឆ្លងមេរោគអេដស៍ -ការរួបរួមគ្នាក្នុងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដើម្បីកាត់បន្ថយជាអតិបរមានូវអត្រាឈឺ និងអត្រាស្លាប់ក្នុងចំណោមអ្នកដែលបានឆ្លង - ការរួបរួមគ្នាក្នុងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដើម្បីកាត់បន្ថយបន្ទុកមេរោគនៅក្នុងសហគមន៍ដែលជាជំនួយសំរាប់ការបង្ការមេរោគអេដស៍ - ការរួបរួមគ្នាក្នុងយុទ្ធសាស្ត្រធ្វើឱ្យប្រសើរឡើងនូវការធ្វើតេស្តរកមេរោគអេដស៍- និងការរួបរួមគ្នាក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងការរើសអើង ។

លោកវេជ្ជបណ្ឌិត Montaner បានបន្ថែមទៀតថា ថ្វីបើចំនួនអ្នកស្លាប់ដោយសារជំងឺអេដស៍បានថយចុះពី ២,២ លាននាក់ក្នុងឆ្នាំ ២០០៥ មកត្រឹម ២ លាននាក់ក្នុងឆ្នាំ ២០០៧ ក៏ដោយ ក៏ចំនួន "២ លាននេះនៅតែជាចំនួនដ៏ច្រើនដដែល!" ។

លោក Peter Piot នាយកប្រតិបត្តិទីភ្នាក់ងារ UNAIDS បាននិយាយថា ពិភពលោកមិនត្រូវភ្លេចថា ការឆ្លងរាលដាលអាចវិលត្រលប់មកវិញជាមួយនឹងភាពភ្ញាក់ផ្អើល ។ លោកបានបន្តទៀតថា "ការរួបរួមក្នុងការបង្ការគឺមានសារៈសំខាន់ខ្លាំងណាស់ ។ ការរួបរួមគ្នាក្នុងការបង្ការទាក់ទិននឹងការគៀងគរ ដើម្បីការផ្លាស់ប្តូរសង្គមមិនឱ្យមានការមាក់ងាយទាក់ទងនឹងអេដស៍តទៅទៀត ។ យើងគ្រប់គ្នាមានគំនិតផ្ទាល់ខ្លួនរបស់យើង! ការធ្វើឱ្យសម្ព័ន្ធភាពកាន់តែធំឡើងគឺមិនត្រូវពង្រីកដោយមិនបានចរចារជាមួយនឹងគ្រប់វិស័យនោះទេ គឺត្រូវឱ្យសង្គមស៊ីវិល និងសង្គមអ្នករស់នៅជាមួយមេរោគអេដស៍មានការពាក់ព័ន្ធ ដែលជាមូលដ្ឋានសំរាប់សកម្មភាពរបស់យើងបែបវិទ្យាសាស្ត្រ ធ្វើអ្វីៗទាំងអស់ដោយឈរលើមូលដ្ឋានសិទ្ធិមនុស្ស និងផ្តោតលើលទ្ធផលសំរាប់មនុស្សជាតិ ។"

ជាការចូលរួមមតិនៅក្នុងពិធីបិទសន្និសីទនោះ លោកវេជ្ជ. Pedro Cahn សហប្រធានសន្និសីទបាននិយាយថា ឥឡូវនេះដល់ពេលដែលថ្នាក់ដឹកនាំពិភពលោក អ្នកវិទ្យាសាស្ត្រ និងសមាជិកសហគមន៍រក្សាការខិតខំប្រឹងប្រែងរបស់ខ្លួនតាមទិសដៅតទៅទៀត ។ លោកបានបន្តថា "តាមផ្លូវត្រលប់ទៅប្រទេសរបស់អស់លោក-លោកស្រីវិញ សូមចង់ចាំថា លោក-លោកស្រីអាចធ្វើឱ្យមានការផ្លាស់ប្តូរ ។ អ្នករស់នៅជាមួយមេរោគអេដស៍ និងមនុស្សរាប់លាននាក់ដែលកំពុងប្រឈមមុខនឹងភយន្តរាយនេះត្រូវការឱ្យលោក-លោកស្រីបំពេញកាតពកិច្ចរបស់ខ្លួនក្នុងសកម្មភាពជាសកលនាពេលនេះ" ។

លោកវេជ្ជ. Magaret Chan អគ្គនាយកអង្គការសុខភាពពិភពលោកបាននិយាយថា "ការខិតខំប្រឹងប្រែងសំរេចការទទួលបានជាសកល" គឺជាការបង្ហាញពីការគោរពនូវតំលៃនៃជីវិតនីមួយៗ ដែលរងផលប៉ះពាល់ដោយសារអេដស៍ ហើយវាគឺជា "ជោគជ័យដ៏ធំសម្បើម" ។ លោកបានបន្ថែមទៀតថា យ៉ាងណាក៏ដោយ ការឆ្លងរាលដាលនេះមិនទាន់ចប់នៅឡើយទេ ។ "យើងត្រូវធ្វើដំណើរវែងឆ្ងាយទៀតក្នុងបេសកកម្មនេះ...។ ការបន្តស្វែងរកសមភាព យុត្តិធម៌ សង្គម និងការទទួលបានជាសកលគឺជាកំលាំងចលករមួយ ។ វាគឺជាវិធីសាស្ត្ររួបរួមគ្នាដែលជំរុញឱ្យមានការចូលរួម និងភាពជាម្ចាស់ពីសហគមន៍ដោយរួមទាំងភាពជាម្ចាស់របស់អ្នករស់នៅជាមួយមេរោគអេដស៍ផងដែរ" ។

*(ដោយ ឆាយ សុផល បកប្រែដោយលោក គឹម រតនា)*

## (តពីទំព័រ ១): ការមាក់ងាយជាចំណុចក្តៅនៅក្នុងសន្និសីទអន្តរជាតិស្តីពីជំងឺអេដស៍នៅម៉ិចស៊ិកូ

អេដស៍នេះ គឺថា សាលារៀនត្រូវបង្រៀនឱ្យមានការគោរពមេដឹកនាំសាសនាត្រូវផ្តល់ធម៌ពីការអត់ឱន ហើយប្រព័ន្ធព័ត៌មានត្រូវថ្កោលទោសពីការធ្វើបុរេវិនិច្ឆ័យនៅក្នុងមូលបទទាំងឡាយរបស់មេរោគនេះ" ។ លោកអគ្គលេខាដោយបានជួបជាមួយសហការីរបស់លោកដែលធ្វើការប្រយុទ្ធនឹងជំងឺអេដស៍ ព្រមទាំងអ្នករស់នៅជាមួយមេរោគអេដស៍ផង ចាប់តាំងពីបានកាន់តំណែងរបស់លោកជាអគ្គលេខាធិការអង្គការសហប្រជាជាតិមក លោកក៏បានទទូចដល់ប្រជាជាតិទាំងអស់ឱ្យ "ពង្រឹងការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីកំណត់ ឬបង្ខំឱ្យមានការដាក់ឱ្យនៅក្រៅច្បាប់ចំពោះការមាក់ងាយដល់អ្នករស់នៅជាមួយមេរោគអេដស៍ និងសមាជិករបស់ក្រុមងាយរងគ្រោះ" ។

ដោយមានការអត្ថាធិប្បាយលើការអំពាវនាវនេះ លោកវេជ្ជ. Margaret Chan អគ្គនាយកនៃអង្គការសុខភាពពិភពលោកបាននិយាយថា ពិភពលោកត្រូវខិតខំធ្វើការបន្ថែមទៀត ដើម្បីកាត់បន្ថយការប្រឈមរួមគ្នានេះ ។ លោកវេជ្ជ. Margaret បាននិយាយថា "យើងត្រូវខំធ្វើការឱ្យខ្លាំងជាងនេះ ដើម្បីប្រយុទ្ធនឹងការមាក់ងាយ និងការរើសអើងដោយបង្កើតឱ្យមានការអប់រំជាស្ថាប័នអំពីការមាក់ងាយនេះ ។ នៅក្នុងប្រទេសជាច្រើន ឧបសគ្គផ្នែកវប្បធម៌ និងសង្គមព្រមទាំងផ្នែកច្បាប់ផង បានទប់ស្កាត់ក្រុមដែលងាយរងគ្រោះពីការទទួលបានការធ្វើអន្តរាគមន៍ និងចំណេះដឹងផ្សេងៗដែលត្រូវការដើម្បីកាត់បន្ថយឥរិយាបទដែលបង្កឱ្យមានភាពគ្រោះថ្នាក់" ។

លោកវេជ្ជ. Pedro Cahn សហប្រធានសន្និសីទស្តីពីជំងឺអេដស៍ឆ្នាំ ២០០៨ នេះ បានបន្ថែមថា "ជាមួយអ្នកទាំងអស់គ្នានៅទីនេះយើងបានបញ្ចេញសំលេងរបស់យើងប្រឆាំងនឹងការមាក់ងាយ និងការរើសអើងដោយប្រឆាំងនឹងវិសមភាពក្នុងសង្គមដែលជាកំលាំងចលករដ៏ចំបងមួយនៃសោកនាដកម្មមនុស្សជាតិ ហើយយើងនិយាយក្នុងនាមអ្នកមានវិជ្ជាជីវៈលើការងារអេដស៍ដែលមកពីបណ្តាប្រទេសនៅជុំវិញពិភពលោក" ។

ដោយជាសហប្រធានសន្និសីទ និងជាអ្នកតំណាងប្រចាំតំបន់របស់ក្រុមប្រឹក្សាគ្រប់គ្រងសង្គមអន្តរជាតិប្រឆាំងជំងឺអេដស៍សំរាប់តំបន់អាមេរិកឡាទីន និងការ៉ាបៀន លោកវេជ្ជ. Luis-Soto Ramirez បាននិយាយនៅក្នុងសន្ទរកថាបើកសន្និសីទថា ការមាក់ងាយ និងការរើសអើង "បន្តគាបសង្កត់ការរីកចម្រើនរបស់យើងក្នុងការទប់ទល់នឹងជំងឺនេះ" ។

មេដឹកនាំពិភពលោកក៏បានសាទរដល់ការសំរេចរបស់សភាសហរដ្ឋអាមេរិក ដើម្បីផ្តល់សិទ្ធិអំណាចដល់ PEPFAR នូវទឹកប្រាក់ចំនួន ៣៩ ពាន់លានដុល្លាសំរាប់ការងារអេដស៍ ដែលជាការផ្តួចផ្តើមគំនិតមួយត្រូវបានចុះហត្ថលេខាជាផ្លូវច្បាប់ដោយលោកប្រធានាធិបតី ជត ដាប់ប៉ាល់យូ ប៊ូស នៅថ្ងៃទី ៣០ កក្កដាកន្លងទៅនេះ ។ ពួកគេក៏បានស្វាគមន៍ពីព័ត៌មានដែលសហរដ្ឋអាមេរិកបានលុបច្បាប់ដែលមានរយៈពេល ២០ ឆ្នាំមកហើយដែលហាមមិនឱ្យអ្នករស់នៅជាមួយមេរោគអេដស៍ចូលទឹកដីអាមេរិកនោះ ។

នៅថ្ងៃបញ្ចប់នៃសន្និសីទនាថ្ងៃទី ៨ សីហា ប្រតិភូក៏បានអំពាវនាវឱ្យលុបច្បាប់ដែលបង្វែរឱ្យទៅជាករណីបទឧក្រិដ្ឋ និងការមាក់ងាយដល់ក្រុមងាយរងគ្រោះចំពោះជំងឺអេដស៍នេះ ។ កាសែតញូយ៉ក ថែមស៍ បានដកស្រង់សំដីលោក Edwin Cameron ប្រធានឧត្តមតុលាការឧទ្ធរក្នុងប្រទេសអាហ្វ្រិកខាងត្បូង ដោយនិយាយថា "ការបង្វែរឱ្យទៅជាករណីបទឧក្រិដ្ឋគឺជាមធ្យោបាយអន់បំផុតសំរាប់ការដាក់បញ្ញត្តិចំពោះការឆ្លង និងការចម្លងមេរោគអេដស៍" ។ បើតាមកាសែត ឌឹ ថែមស៍ បានឱ្យដឹងថា លោកតុលាការយុត្តិធម៌ Cameron ដែលមានផ្ទុកមេរោគអេដស៍ដែរនោះបាននិយាយថា "សូមឱ្យលទ្ធផលមួយក្នុងចំណោមលទ្ធផលជាច្រើនរបស់សន្និសីទនេះក្លាយជាការជំរុញការគាំទ្រជាអន្តរជាតិដ៏សំខាន់ក្នុងការប្រឆាំងនឹងច្បាប់ឧក្រិដ្ឋ និងការដាក់ទោសទណ្ឌទាំងឡាយដែលនាំឱ្យមានការភាន់ច្រឡំនោះ" ។

នៅក្នុងអត្ថបទបញ្ចេញមតិមួយនៅក្នុងកាសែត វ៉ាស៊ីនតោន ថែមស៍ ចុះថ្ងៃទី ៦ សីហា លោកអគ្គលេខាអង្គការសហប្រជាជាតិបានសរសេរថា "ការមាក់ងាយនៅតែជាឧបសគ្គតែមួយគត់ដ៏ចំបងបំផុតសំរាប់សកម្មភាពសាធារណៈ ។ បញ្ហានេះជាហេតុផលដ៏សំខាន់ដែលធ្វើឱ្យមនុស្សជាច្រើនខ្លាចមិនហ៊ានទៅឱ្យគ្រូពេទ្យពិនិត្យដើម្បីសំរេចថាតើពួកគេមានជំងឺឬអត់ ឬក៏សុំឱ្យមានការព្យាបាលជាដើម ។ លោកបានបញ្ជាក់ថា ការមាក់ងាយជាហេតុផលដ៏ធំនៃការរីករាលដាលមេរោគអេដស៍ ដែលជាឃាតករស្ងាត់ស្ងៀមនោះនៅបន្តបង្ហិនបង្ហោចសង្គមនានានៅជុំវិញពិភពលោកនេះ ។

*(ដោយ ឆាយ សុផល)*




*លោក Ban Ki-moon អគ្គលេខាធិការអង្គការសហប្រជាជាតិ ថ្លែងសន្ទរកថាបើកសន្និសីទអន្តរជាតិលើកទី ១៧ ស្តីពីជំងឺអេដស៍ដោយបានផ្តោតលើសកម្មភាពជាសកលនាពេលបច្ចុប្បន្នកាលពីថ្ងៃទី ៣ សីហា ក្នុងទីក្រុងម៉ិចស៊ិកូ ។ (រូបថតUN/Evan Schneider)*

# មេដឹកនាំប្រទេស G8 ទទួលសំពាធឱ្យមានការឆ្លើយតបនឹងអេដស៍

នៅថ្ងៃចុងក្រោយនៃសន្និសីទអន្តរជាតិលើកទី ១៧ ស្តីពីជំងឺអេដស៍ ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី ៣ ដល់ ៨ សីហា កន្លងទៅនេះនាទីក្រុងម៉ិចស៊ិកូ ប្រទេសមហាអំណាចឧស្សាហកម្មទាំង ៨ ឬហៅថាប្រទេស G8 ត្រូវបានគេទទូចឱ្យធ្វើសកម្មភាពបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងជំងឺអេដស៍ ដែលជាឃាតករស្ងាត់ស្ងៀមនៅក្នុងពិភពលោក។

Michel Kazatchkine នាយកប្រតិបត្តិនៃមូលនិធិសកលប្រយុទ្ធនឹងជំងឺអេដស៍ របេង និងគ្រុនចាញ់បាននិយាយនៅឯពិធីបិទសន្និសីទដែលមានរយៈពេល ៦ ថ្ងៃនោះថា ពិភពលោក "គួរតែបារម្ភឱ្យបានខ្លាំងដែលថា ក្នុងរយៈពេលតិចជាង ២ ឆ្នាំខាងមុខនេះ ពេលវេលា




*លោកបណ្ឌិត Julio Montaner ថ្លែងសន្ទរកថាបិទអង្គសន្និសីទអន្តរជាតិលើកទី ១៧ ស្តីពីជំងឺអេដស៍នៅ ក្នុងប្រទេសមិចស៊ិកូនាថៃទី ៨ សីហា។ (រូបដោយ Henry Lin)*

កំណត់របស់យើងសំរាប់ការទទួលបានជាសលកនោះ ប្រទេស G8 បានលះបង់ដ៏តិចតួច គឺច្រើនជាងមួយភាគបីតែប៉ុណ្ណោះនៃធនធានដែលខ្លួនបានសន្យាផ្តល់ឱ្យនៅត្រឹមឆ្នាំ ២០១០។

នៅក្នុងសន្ទរកថាបិទរបស់លោក លោកបណ្ឌិត Julio Montaner នាយកមជ្ឈមណ្ឌលនៃទីភ្នាក់ងារ Excellence in HIV/AIDS នៅក្នុងទីក្រុង Vancouver ប្រទេសកាណាដា និងជាប្រធានថ្មីរបស់អង្គការសង្គមអន្តរជាតិប្រយុទ្ធនឹងជំងឺអេដស៍បាននិយាយថា មាន "ការប្តេជ្ញាចិត្តដ៏ធំ" ចំពោះភាគីសហរដ្ឋអាមេរិក ដែលបានរួមចំណែកនូវទឹកប្រាក់ ៤៨ ពាន់លានដុល្លា ចំពោះការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ របេង និងគ្រុនចាញ់ ហើយការទទួលខុសត្រូវបែបនេះមិនអាចពឹងផ្អែកតែលើបន្ទុករបស់អាមេរិកតែឯងនោះទេ។ លោកបណ្ឌិតបាននិយាយថា "ពិភពលោកគួរដើរតាមលំនាំដែលមានជាឧទាហរណ៍នេះ។ ទីបំផុតប្រសិនបើលោកប្រធាននាយកធិបតី ប៊ូស បានទទួលរ៉ាប់រងបញ្ហានេះហើយនោះមេដឹកនាំនៃប្រទេស G8 គួរទទួលយកបញ្ហានេះដែរ!" ។ លោកបណ្ឌិតក៏បានអំពាវនាវផងដែរដល់លោក Stephen Harper នាយករដ្ឋមន្ត្រីកាណាដា ឱ្យចូលរួមជាមួយមេដឹកនាំនៃបណ្តាប្រទេស G8 "ដើម្បីរួមជាមួយវិភាគទានរបស់លោកប្រធាននាធិបតី ប៊ូស នាពេលឥឡូវនេះ!... យើងត្រូវតែរក្សាការដាក់សំពាធដល់មេដឹកនាំប្រទេស G8 នេះ ដើម្បីតាមមើលលើការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការសំរេចនូវការទទួលបានជាសលកលើការបង្ការ ការថែទាំ និងការព្យាបាលនៅឆ្នាំ ២០១០" ។

ថ្លែងនៅក្នុងពិធីបើកសន្និសីទកាលពីថ្ងៃទី ៣ សីហា លោក Ban Ki-moon អគ្គលេខាធិការអង្គការសហប្រជាជាតិបានលើកឡើងថា មូលនិធិគឺត្រូវការចាំចាច់បន្ថែមទៀតនៅក្នុងទស្សវត្សខាងមុខៗ ដើម្បីប្រយុទ្ធនឹងជំងឺអេដស៍ "។ លោកបាននិយាយថា "ដោយសារតែការប្រយុទ្ធនឹងជំងឺអេដស៍បានខិតជិតមកដល់នៅក្នុងដំណាក់កាលនៃទស្សវត្សទីបីហើយនោះ យើងនៅតែប្រឈមមុខជាមួយនឹងកង្វះខាតធនធានដ៏ច្រើនដដែល។ ការឆ្លើយតបទាំងឡាយទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍គឺតម្រូវឱ្យមានហិរញ្ញវត្ថុដែលមានរយៈពេលវែង និងមាននិរន្តភាព"។ លោកបានបញ្ជាក់ថា "ដោយសារតែមានមនុស្សជាច្រើនបន្តការព្យាបាលហើយរស់នៅឱ្យបានយូរនោះ ថវិកានឹងត្រូវតែបង្កើនឱ្យបានច្រើនសំរាប់រយៈពេលពីរបីទស្សវត្សខាងមុខនេះទៀត។ នៅក្នុងបណ្តាប្រទេសដែលរងផលប៉ះពាល់ខ្លាំងនោះ ម្ចាស់មូលនិធិនឹងត្រូវផ្តល់ថវិកាឱ្យបានភាគច្រើនបំផុត"។ លោកក៏បានសន្យាដែរថា លោកនឹងធ្វើការដើម្បី "គៀងគរធនធាន និងធ្វើឱ្យប្រាកដថា ជំងឺអេដស៍នឹងនៅតែជាប្រព័ន្ធអទិភាពមួយដ៏ធំរបស់អង្គការសហប្រជាជាតិ"។

ក្នុងឆ្នាំ ២០០៥ ប្រទេស G8 បានកំណត់គោលដៅក្នុងការផ្តល់ការថែទាំមេរោគអេដស៍ដល់អ្នកទាំងឡាយ ដែលត្រូវការនៅឆ្នាំ ២០១០។ ប្រទេស G8 រួមមាន: ប្រទេសអាឡឺម៉ង់ កាណាដា សហរដ្ឋអាមេរិក បារាំង អ៊ីតាលី ជប៉ុន អង់គ្លេស និងប្រទេសរូស្ស៊ី។

*(ដោយ ឆាយ សុផល បកប្រែដោយ លោក ទូត សុវណ្ណារី)*

## *(តពីទំព័រ ១):* បើគ្មានថ្នាំប្រឆាំងមេរោគអេដស៍ទេ នោះគឺជាការលំបាក ដល់អ្នករស់នៅជាមួយមេរោគអេដស៍

ហៀង សុខហេង គឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សរាប់ម៉ឺននាក់នៅក្នុងប្រទេសកម្ពុជាដែលកំពុងរស់នៅជាមួយមេរោគអេដស៍។ ទោះបីជាអត្រានៃការចម្លងមេរោគនេះបានធ្លាក់ចុះពី ១,២% នៅឆ្នាំ ២០០៣ មកនៅត្រឹម ០,៩% ក្នុងឆ្នាំ ២០០៦ ក៏ដោយ ក៏អត្រាប្រេវ៉ាឡង់ក្នុងចំណោមស្ត្រីរៀបការរួចបានឆ្លងពីស្វាមីរបស់គេនៅតែខ្ពស់ ខណៈដែលមួយភាគបីនៃការចម្លងថ្មីៗកើតមានពីម្តាយទៅកូន។

មន្ត្រីមួយរូបនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បាននិយាយថា ថ្នាំប្រឆាំងមេរោគអេដស៍នឹងនៅតែជាតម្រូវការដ៏ខ្ពស់ដែលយ៉ាងហោចណាស់ក៏រយៈពេល ២ ឆ្នាំខាងមុខនេះដែរ។ លោកវេជ្ជបណ្ឌិត ហោ ប៊ុនឡេង អគ្គលេខាធិការរងនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បាននិយាយថា "ស្ត្រីប្រមាណជា ១៨,៣០០ នាក់ និងបុរស ១៧,០០០ នាក់នឹងត្រូវការថ្នាំប្រឆាំងមេរោគអេដស៍នេះរវាងឆ្នាំ ២០០៨ និងឆ្នាំ ២០១០។ លោកបាន ប៉ាន់ប្រមាណថា មនុស្សដែលរស់នៅជាមួយមេរោគអេដស៍ម្នាក់អាចចំណាយអស់ប្រហែលមួយពាន់ដុល្លារក្នុងមួយឆ្នាំសម្រាប់ថ្នាំប្រឆាំងមេរោគអេដស៍នេះ។ លោកវេជ្ជ-បណ្ឌិត ប៊ុនឡេង ក៏បានព្រមានផងដែរថា ការរាលដាលអាចកើតមានជាថ្មី ប្រសិនបើប្រទេសនៅស្ទាក់ស្ទើរក្នុងការចាត់វិធានការសម្រាប់ការការពារបន្ថែម។ លោកបានបន្ថែមថា ក្រុមអ្នកងាយរងគ្រោះនៅចន្លោះពីអាយុ ១៥-៤៩ ឆ្នាំ ដូចជាជនចំណាកស្រុក ស្ត្រីបំរើសេវាកំសាន្តបុរសស្រឡាញ់បុរស អ្នកសេពគ្រឿងញៀន និងស្ត្រីរៀបការរួចមានអត្រាគ្រោះថ្នាក់ខ្ពស់ ហើយអត្រាមរណៈខ្ពស់ដោយសារជំងឺអេដស៍នេះហើយ បានបន្សល់ទុកកុមារកំព្រា និងស្ត្រីមេម៉ាយជាច្រើន។



*ហៀង សុខហេង កាន់រូបថតសពម្តាយរបស់នាង។ ជឿន រឿន ដែលជាជីដូនរបស់នាងអំពាវនាវដល់ពិភពលោកឱ្យរកថ្នាំព្យាបាលជំងឺអេដស៍ដែលអាចជួយព្យាបាលចៅស្រីរបស់គាត់ និងអ្នករស់នៅជាមួយមេរោគអេដស៍ឯទៀតៗ ។*

ស្ថានភាពបែបនេះត្រូវបានរាលដាលពាសពេញពិភពលោក។ ការខំប្រឹងប្រែងរបស់អ្នកស្រាវជ្រាវ និងអ្នកផលិតថ្នាំទាំងឡាយដែលធ្វើការរួមគ្នាដើម្បីផលិត និងចែកចាយថ្នាំប្រឆាំងមេរោគអេដស៍កំពុងជួយសង្គ្រោះជីវិតអ្នករស់នៅជាមួយមេរោគអេដស៍ទាំងនោះ។ លោក Festus G. Mogae អតីតប្រធានាធិបតីនៃប្រទេសប៊ុតស្វាណា បាននិយាយនៅក្នុងសន្ទរកថាបើកកម្មវិធីរបស់លោកកាលពីថ្ងៃទី ៣ សីហានៅឯសន្និសីទអន្តរជាតិស្តីពីជំងឺអេដស៍លើកទី ១៧ ថា "មនុស្សបីលាននាក់ដែលទទួលបានការព្យាបាលដោយថ្នាំប្រឆាំងមេរោគអេដស៍នៅពាសពេញពិភពលោក គឺមិនគ្រាន់តែជាសម្មិទ្ធផលនៃសេវាកម្មសុខភាពដ៏អស្ចារ្យនៅក្នុងសតវត្សថ្មីនេះប៉ុណ្ណោះទេ តែវាក៏ជាវិភាគទានមួយសម្រាប់អ្នកទាំងឡាយដែលបានព្យាយាមស្វែងយល់ពីអេដស៍ និងធ្វើឱ្យងាយរកបានថ្នាំប្រឆាំងមេរោគអេដស៍ដើម្បីជួយសង្គ្រោះជីវិតមនុស្ស "។ លោក Mogae ក៏បាននិយាយផងដែរថា លោកគោរព និងទទួលស្គាល់តួនាទីដ៏សំខាន់របស់ក្រុមហ៊ុនផលិតឱសថជាច្រើនដែលត្រូវគេបន្ទោសជាញឹកញាប់នៅក្នុងពិភពលោក។

ថ្លែងនៅក្នុងសន្ទរកថាបើកនៅឯសន្និសីទនោះដែរ លោក Peter Piot នាយកប្រតិបត្តិនៃទីភ្នាក់ងារ UNAIDS ក៏បានទទូចឱ្យអ្នកវិទ្យាសាស្ត្រ និងអ្នកផ្តល់មូលនិធិទាំងអស់បន្តការខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបង្កើតឱសថបង្ការមេរោគអេដស៍ ដែលអាចឱ្យមនុស្សជាច្រើនមានឱកាសរកបានថ្នាំនេះ។ លោកបាននិយាយថា "នៅលើកំណាត់ផ្លូវដ៏វែងឆ្ងាយ វិធីដែលល្អបំផុតក្នុងការបញ្ឈប់ការស្លាប់របស់មនុស្សពីជំងឺអេដស៍គឺត្រូវតែកាត់បន្ថយការចម្លងថ្មីៗដែលជាកត្តាដំបូង។ ប៉ុន្តែនៅគ្រានេះដែរ ការព្យាបាលត្រូវតែរក្សាឱ្យបានខ្លាំងក្លាដូចពីមុនដដែល ព្រោះយើងមិនត្រូវបំភ្លេច ថានេះគឺធ្វើដើម្បីមនុស្សជាតិ។ ព្រោះនេះគឺជាសិទ្ធិទទួលបាននៅជីវិតរស់នៅ"។ លោកបានបន្តថា "មេរៀនមួយក្នុងចំណោមមេរៀនចម្បងជាច្រើននៃការផ្តល់ថ្នាំប្រឆាំងមេរោគអេដស៍ដល់មនុស្សរាប់លាននាក់គឺថា យើងមិនត្រូវនៅរង់ចាំរហូតដល់ប្រព័ន្ធទាំងឡាយត្រូវបានជួសជុលមុនពេលមានសកម្មភាពនោះទេ ពីព្រោះខ្ញុំដឹងថា អ្វីដែលបានកើតឡើងដល់មនុស្សបីលាននាក់នោះ និងថ្នាំប្រឆាំងមេរោគអេដស៍នាសព្វថ្ងៃនេះ ប្រសិនយើងបានរង់ចាំនោះ គឺពួកគេភាគច្រើនបានស្លាប់រួចទៅហើយមកដល់ពេលឥឡូវនេះ"។

នៅក្នុងសន្ទរកថាបើកសន្និសីទ លោកវេជ្ជ. Luis-Soto Ramirez សហប្រធាន និងជាតំណាងប្រចាំតំបន់របស់ក្រុមប្រឹក្សាគ្រប់គ្រងសង្គមអន្តរជាតិប្រឆាំងជំងឺអេដស៍សំរាប់តំបន់អាមេរិកឡាទីន និងការ៉ាបៀនបាននិយាយថា ប្រទេសមួយចំនួននៅក្នុងតំបន់បានជំទាស់ទៅនឹងគំនិតដែលថា ការព្យាបាលអាចមានឱកាសសម្រាប់ "អ្នកមានសំណាងមួយចំនួនតូចប៉ុណ្ណោះដែលមានលុយសម្រាប់ចំណាយលើថ្នាំប្រឆាំមេរោគអេដស៍" ហើយប្រទេសទាំងនោះកំពុងតែខិតខំប្រឹងប្រែងក្នុងការទម្លាក់តម្លៃថ្នាំនេះ ដើម្បីជាស្ពានបំពេញចន្លោះរវាងតំបន់ខាងជើង និងតំបន់ខាងត្បូង។ លោកបាននិយាយថា "វាដល់ពេលនាំថ្នាំឱ្យមនុស្សគ្រប់ៗរូបដែលត្រូវការហើយដោយមិនគិតថា ពួកគេជានរណា ពួកគេរស់នៅឯណា ឬថាតើពួកគេរកចំណូលបានប៉ុន្មានយ៉ាងណានោះទេ។ វាដល់ពេលហើយឥឡូវនេះសម្រាប់សកម្មភាពជាសកល" ។

នៅក្នុងសន្ទរកថាបិទសន្និសីទ លោកវេជ្ជ. Julio Montaner នាយកនៃមជ្ឈមណ្ឌលកូឡុំប៊ី ចក្រភពអង់គ្លេស ដើម្បីឧត្តមភាពក្នុងការឆ្លើយតបនឹងមេរោគអេដស៍/ជំងឺអេដស៍នៅរដ្ឋវែនកូវ័រប្រទេសកាណាដា និងជានាយកថ្មីនៃអង្គការសង្គមអន្តរជាតិប្រយុទ្ធនឹងជំងឺអេដស៍បាននិយាយថា បើទោះជាចំនួនកុមារឆ្លងមេរោគអេដស៍បានធ្លាក់ចុះពី ៤១០.០០០ នាក់ក្នុងឆ្នាំ ២០០៥ មកនៅ ៣៧០.០០០ ក្នុងឆ្នាំ ២០០៧ ក៏ដោយ ក៏ចំណុចនេះគឺជាជោគជ័យមួយដ៏លំបាក..."។

ប្រសិនបើការអំពាវនាវពីមេដឹកនាំ និងប្រតិភូទាំងអស់នៅឯសន្និសីទនោះអាចសម្រេចបាន នោះវាជាដំណឹងល្អសម្រាប់កុមារី ហៀង សុខហេង និងអ្នកដែលរស់នៅជាមួយមេរោគអេដស៍ដទៃៗទៀតនៅលើពិភពលោក។ ជីដូនកុមារី សុខហេង បាននិយាយថា "ខ្ញុំពិតជាសប្បាយរីករាយណាស់ ប្រសិនបើអ្នកដែលរស់ជាមួយមេរោគអេដស៍ទាំងអស់អាចទទួលបានថ្នាំប្រឆាំងមេរោគអេដស៍នេះដោយទ្បេងទាត់ឥតគិតថ្លៃ។ ខ្ញុំសូមអំពាវនាវដល់គ្រូពេទ្យទាំងអស់ឱ្យផលិតថ្នាំប្រឆាំងមេរោគអេដស៍នេះឱ្យបានច្រើនសម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍ និងស្វែងរកថ្នាំបង្ការអេដស៍ ដើម្បីឱ្យចៅស្រីខ្ញុំ និងអ្នកដទៃៗទៀតដែលរស់ជាមួយមេរោគអេដស៍អាចរស់បានកាន់តែយូរ"។

*(ដោយ ឆាយ សុផល បកប្រែដោយលោក ទា ពុទ្ធារ៉ា)*

# តើអ្វីជាសន្និសីទអេដស៍អន្តរជាតិ?



*អ្នកស្រី មករា ស្ត្រីមេម៉ាយវ័យ ៣៥ ឆ្នាំរស់នៅជាមួយមេរោគអេដស៍ រៀបចំកូនប៊ីយ៉ាឱ្យអតិថិជនក្មេងៗនៅក្នុងផ្ទះរបស់គាត់ ។ អ្នកស្រីនិយាយថា គាត់មិនដែលដឹងពីសន្និសីទអន្តរជាតិស្តីពីអេដស៍ លើកទី ១៧ នៅប្រទេសម៉ិចស៊ិកូនោះទេ ។*

ខណៈដែលមេដឹកនាំពិភពលោក អ្នករៀបចំគោលយោបាយ សកម្មជនការងារអេដស៍ និងអ្នករស់នៅជាមួយមេរោគអេដស៍ រាប់ពាន់នាក់បានជួបប្រជុំគ្នានៅអំឡុងពេលសន្និសីទអន្តរជាតិលើកទី ១៧ ស្តីពីជំងឺអេដស៍នៅប្រទេសម៉ិចស៊ិកូនៅថ្ងៃទី ៣-៨ សីហា កន្លងមកនេះ អ្នករស់នៅជាមួយមេរោគអេដស៍ដែលជាជនជាតិកម្ពុជាបានដឹងតិចតួចពីបញ្ហានេះ ។ "ខ្ញុំពិតជាមិនបានដឹងអ្វីទាល់តែសោះអំពីសន្និសីទនេះ អញ្ចឹងហើយខ្ញុំមិនដឹងថាគេនិយាយពីអ្វីនោះទេ ។ តើពួកគេរកវ៉ាក់សាំងអេដស៍បានឬនៅ?" នេះជាសំណួររបស់អ្នកស្រី មករា ជាស្ត្រីមេម៉ាយអាយុ ៣៥ ឆ្នាំដែលរស់នៅជាមួយមេរោគអេដស៍ ។

រស់នៅក្នុងក្រុងព្រះសីហនុដែលជាទីក្រុងកំពង់ផែអន្តរជាតិ និងជាទីក្រុងលំហែរកាយស្ថិតនៅប៉ែកនិរតីនៃប្រទេស អ្នកស្រី មករា ជារឿយៗតែងតែឃើញគេរាយការណ៍ពីមេរោគអេដស៍ និងជំងឺអេដស៍ នៅតាមទូរទស្សន៍ និងនៅតាមកាសែត ប៉ុន្តែគាត់មិនបានឃើញសេចក្តីរាយការណ៍ណាមួយពីសន្និសីទនៅម៉ិចស៊ិកូនោះទេ ។ គាត់បាននិយាយថា "ខ្ញុំមើលទូរទស្សន៍ញឹកញាប់ណាស់ តែខ្ញុំមិនដែលឃើញសេចក្តីរាយការណ៍ណាមួយពីសន្និសីទនេះឡើយ" ។

អ្នកអប់រំអំពីអេដស៍ និងអ្នករស់នៅជាមួយមេរោគអេដស៍ ជាច្រើនដែលត្រូវបានសម្ភាស ក៏បាននិយាយដែរថា ពួកគេក៏មិនដឹងពីព្រឹត្តិការណ៍សកលនេះដែរ ។ ស្ត្រីមេម៉ាយម្នាក់ផ្សេងទៀត អាយុ ៣៨ ឆ្នាំដែលរស់នៅជាមួយមេរោគអេដស៍បាននិយាយថា "ខ្ញុំស្តាប់វិទ្យុ តែខ្ញុំមិនដែលឮព័ត៌មានពីសន្និសីទនេះសោះ" ។

ថ្លែងនៅក្នុងសន្ទរកថាបិទវគ្គនៅឯសន្និសីទស្តីពីជំងឺអេដស៍ ដែលមានរយៈពេល ៦ ថ្ងៃ លោកវេជ្ជ. Julio Montaner ប្រធានសង្គមអន្តរជាតិប្រយុទ្ធនឹងជំងឺអេដស៍បាននិយាយថា អ្នករៀបចំសន្និសីទនេះបានចំណាយលើប្រតិភូជាង ២.៥០០ នាក់មកពីប្រទេសចំនួន ៩៥ ។ លោកបាននិយាយថា អ្នករៀបចំក៏បាន "ជំពាក់គុណដល់សមាជិកនៃប្រព័ន្ធផ្សព្វ-ផ្សាយព័ត៌មានដែលបានចូលរួមជាមួយយើងនៅក្នុងសន្និសីទនៅម៉ិចស៊ិកូនេះ ។ ពួកគេធ្វើការដោយមិននឿយហត់ ដើម្បីផ្ចិតយកទិដ្ឋភាពទាំងអស់នៅក្នុងសន្និសីទនេះ ។ ការងាររបស់គេគឺ តំណាងឱ្យផ្នែកមួយដ៏មានសារៈសំខាន់នៃដំណោះស្រាយ ដោយការងារនេះផ្តល់ចំណេះដឹងយ៉ាងមានប្រសិទ្ធភាព និងទាន់ពេលវេលាស្តីពីដំណើរការនានារបស់យើង" ។

តែទោះបីជាយ៉ាងនេះក្តីក៏គ្មានអ្នកកាសែតជាតិកម្ពុជាណាម្នាក់ត្រូវបានគេអញ្ជើញឱ្យទៅយកព័ត៌មាននៅឯសន្និសីទនោះទេ បើទោះជាមានអ្នកតំណាងពីអង្គការរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលមួយចំនួនបានចូលរួមក៏ដោយ ។ លោក ប៉ែន សម្មិទ្ធិ និពន្ធនាយកកាសែតរស្មីកម្ពុជាដែលជាកាសែតនាំមុខគេនៅក្នុងប្រទេសបាននិយាយថា លោកក៏មានការភ្ញាក់ផ្អើលដែរ ដែលគេមិនបានអញ្ជើញអ្នកកាសែតកម្ពុជានោះ ។ លោក សម្មិទ្ធិ ដែលជាប្រធានក្លឹបអ្នកកាសែតកម្ពុជាដោយសមាជិករបស់ខ្លួនមានចំនួនជិត ២០០ នាក់នោះ បាននិយាយថា លោកចង់ឱ្យមិត្តរួមការងាររបស់លោកបានចូលរួមសន្និសីទនេះដែរ ដើម្បីយកព័ត៌មានស្តីពីការវិវឌ្ឍ និងរឿងរ៉ាវផ្សេងៗទៀតនៅខាងក្រៅអង្គសន្និសីទនេះ ។ *(ដោយ ឆាយ សុផល បកប្រែដោយលោក ទា ពុទ្ធារ៉ា)*



*អ្នកស្រី ចិន្តា (ស្តាំ) ជាស្ត្រីមេម៉ាយអាយុ ៣៨ ឆ្នាំរស់នៅជាមួយមេរោគអេដស៍ លក់ចេកចៀនឱ្យក្មេងដែលនៅក្បែរផ្ទះរបស់គាត់ ខណៈដែលអ្នកយកព័ត៌មានកំពុងសម្ភាស ។ អ្នកស្រី ចិន្តា និយាយថា គាត់មិនបានដឹងពីសន្និសីទអន្តរជាតិលើកទី ១៧ ស្តីពីអេដស៍នៅប្រទេសម៉ិចស៊ិកូឡើយ ។*

**សន្និសីទជាតិលើកទី ៣ ស្តីពីជំងឺអេដស៍នឹងប្រព្រឹតទៅនៅថ្ងៃទី ១០-១២ កញ្ញា នៅឯសាលសន្និសីទចតុមុខ ។**

# វេទិកាអង្គការខាណា

## *ខាណាសូមស្វាគមន៍ចំពោះបុគ្គលិកមួយរូបដែលបានចូលរួមក្នុងក្រុមគ្រួសារខាណានៅខែ សីហា ២០០៨ នេះ*



**ព្រហ្ម ចាន់រិទ្ធ**

បានក្លាយជាមន្ត្រីផែនការ និងរបាយការណ៍ នៅនាយកដ្ឋានព័ត៌មានយុទ្ធសាស្ត្រនៅថ្ងៃទី ១៨ សីហា នេះ ។ មុនចូលធ្វើការនៅខាណា ចាន់រិទ្ធ បានធ្វើការនៅអង្គការសកម្មភាពដើម្បីសុខភាព (AFH) ជាប្រធានគំរោងនៅក្នុងគំរោងមូលនិធិសមធម៌សុខភាព ។ លោកមានបទពិសោធន៍ក្នុងការរៀបចំផែនការសកម្មភាព ការគ្រប់គ្រងគំរោង ត្រួតពិនិត្យនិងវាយតំលៃ និងសរសេររបាយការណ៍ ។

"ខ្ញុំមានការរីករាយយ៉ាងខ្លាំងដែលបានធ្វើការជាមួយខាណា ។ ខ្ញុំប្តេជ្ញាដើម្បីប្រើប្រាស់ចំណេះដឹងរបស់ខ្ញុំនៅក្នុងការងារ និងបានស្វែងយល់បន្ថែមទៀតពីខាណា" ។

### *ខាណាក៏រីករាយ និងមានមោទនភាពចំពោះបុគ្គលិកមួយរូប*



គឺលោកស្រី ហ៊ុល ស៊ីវ៉ាន់ថា ដែលបានប្រសូតបានកូនស្រីមួយជាលើកដំបូងដ៏ស្រស់ស្អាតនៅថ្ងៃទី ១៩ សីហា នេះ ។ យើងសូមជូនពរដល់លោកស្រី និងក្រុមគ្រួសារទាំងមូល!

## *យើងក៏សូមចូលរួមរីករាយខួបកំណើតរបស់សមាជិកពីររូបរបស់ខាណាដែរ*



Sarah Knibbs មន្ត្រីគាំទ្របច្ចេកទេសរបស់ក្រុមការងារគ្រប់គ្រងជាន់ខ្ពស់របស់ខាណា មានអាយុ ៤១ ឆ្នាំហើយ ថ្ងៃទី ១៨ សីហា ២០០៨ នេះ ។ រីករាយថ្ងៃខួបកំណើតរបស់លោកស្រី!



គន្ធ សុមេធ អ្នកជំនួយការផ្នែកការងារធនធានមនុស្សមានអាយុ ២៧ ឆ្នាំហើយនៅថ្ងៃទី ២៦ សីហានេះ ។ រីករាយថ្ងៃខួបកំណើតរបស់លោក!

## *ខាណាក៏សូមជូនពរដល់អ្នកស្ម័គ្រចិត្តពីររូបដែលបានចាកចេញពីខាណានៅខែ សីហានេះ ដើម្បីការងារថ្មីរបស់ខ្លួន ។*



**ស៊ុន ប៊ុនណេ**

អ្នកជំនួយការស្ម័គ្រចិត្តឱ្យផ្នែកគ្រប់គ្រងកម្មវិធី បានចាកចេញនៅថ្ងៃទី ១១ សីហា ដើម្បីការងារថ្មីរបស់ខ្លួន ។ សូមអបអរសាទរ !

**ថេង ច័ន្ទរតនា**

អ្នកជំនួយការស្ម័គ្រចិត្តនៅផ្នែកគ្រប់គ្រងកម្មវិធី បានចាកចេញនៅថ្ងៃទី ២៥ សីហា បន្ទាប់ពីរយៈពេលជិតមួយឆ្នាំជាមួយខាណា ។ លោកទទួលបានការងារថ្មី ។ សូមអបអរសាទរ !



ព្រឹត្តិបត្រពណិស្វាយរបស់អង្គការខាណាគឺជាព្រឹត្តិបត្រព័ត៌មានប្រចាំខែដែលបង្ហាញពីរឿងរ៉ាវនៃជីវិតរបស់អ្នកដែលទទួលរងផលប៉ះពាល់ និងរស់នៅជាមួយនឹងមេរោគអេដស៍ និងជម្ងឺអេដស៍ ។ ការចេញផ្សាយនេះក៏លើកឡើងពីការយល់ដឹងដ៏សំខាន់អំពីផលប៉ះពាល់នៃមេរោគអេដស៍ និងជម្ងឺអេដស៍នៅក្នុងសហគមន៍ជាតិ និងអន្តរជាតិទូទៅ ។

គណៈកម្មាធិការទទួលបន្ទុកការងារទំនាក់ទំនងរបស់អង្គការខាណាទទួលខុសត្រូវក្នុងការរៀបចំ និងអភិវឌ្ឍព្រឹត្តិបត្រប្រចាំខែនេះ ហើយខ្លឹមសារគឺមិនឆ្លុះបញ្ចាំងពីគំនិត និងទស្សនៈរបស់

*ព័ត៌មានបន្ថែម សូមទាក់ទង លោក ឆាយ សុផល អ្នកសម្របសម្រួលផ្នែកទំនាក់ទំនង*
*តាមរយៈអ៊ីម៉ែល: csophal@khana.org.kh*
*ទូរស័ព្ទ: ០២៣ ២១១ ៥០៥ - ទូរសារ: ០២៣ ២១៤ ០៤៩*
*គេហទំព័រ: www.khana.org.kh*
*ផ្ទះលេខ ៣៣ ផ្លូវលេខ ៧១ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ*

Khana is a linking organisation of the global partnership
International HIV/AIDS Alliance
Supporting community action on AIDS in developing countries